# ប្រកាសរួម

# ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន និង ក្រសួងសុខាភិបាល

ភ្នំពេញ , ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៤

## ប្រកាសរួម លេខ ០៨ សកអ / ៩៤

## ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន និង

## ក្រសួងសុខាភិបាល

* * *

## ស្តីពីការចាត់តាំង បណ្តាញពេទ្យការងារ

## រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង

## អតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៩៩ ក្រ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩២

## សំរេច

**ប្រការ ១ ៈ** គ្រប់រោងចក្រសហគ្រាសគ្រឹះស្ថានឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវាកម្ម សហគ្រាស ដឹកជញ្ជូនតាមផ្លូវថ្នល់ ឬ តាមទន្លេ ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាល សាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយទោះបីជាមាន លក្ខណៈ ជាការបង្រៀនវិជ្ជាជីវៈជាការកុសលក៏ដោយត្រូវរៀបចំចាត់តាំងបណ្តាញពេទ្យការងារ ដើម្បីធានាសន្តិសុខការងារ អនាម័យការងារ និង សុខភាពរបស់និយោជិក និង កម្មកររបស់ខ្លួន ។ ក៏ប៉ុន្តែមិនត្រូវអនុវត្តបទបញ្ញត្តិនេះ ចំពោះរោងជាងទាំងឡាយណាដែលមានប្រើតែ និយោជិកជា សមាជិក នៃគ្រួសារ ដែលឋិតនៅ ក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ ឬ អាណាព្យាបាលប៉ុណ្ណោះ លើកលែងតែការងារប្រព្រឹត្តទៅដោយ ឡចំហាយ ឬ

គ្រឿងយន្ត ឬ អគ្គីសនី ឬ ក៏ឧស្សាហកម្ម នោះជាគ្រឹះស្ថានដែលអាចមានគ្រោះថ្នាក់ ឬ ខូចសុខភាព ។

សហគ្រាស និង គ្រឹះស្ថានដែលចង្អុលក្នុងមាត្រា ១ នៃ ច្បាប់ការងារ ត្រូវអោយមានព្យាបាលជម្ងឺដោយឥតគិតថ្លៃ សំរាប់អ្នកស៊ីឈ្នួលទៀងទាត់របស់ខ្លួន និង គ្រួសារអ្នកស៊ីឈ្នួលទាំងនោះ ។

**ប្រការ ២ :** គ្រប់រោងចក្រសហគ្រាស និង ក្រុមហ៊ុនដែលបានចែងក្នុងប្រការ ១ ហើយដែលមានប្រើអ្នកស៊ីឈ្នួលយ៉ាងតិច ៥០ នាក់ ត្រូវរៀបចំគិលានដ្ឋានអចិន្ត្រៃយ៍មួយអោយបានសមរម្យតាមល័ក្ខខ័ណ្ឌខាងក្រោម ÷

- មានទំហំសមស្របទៅតាមចំនួនបុគ្គលិក កម្មករ ប៉ុន្តែយ៉ាងតូចបំផុតអោយមាន ទំហំផ្ទៃ ១៦ ម៉ែត្រក្រឡា ។
- មានភាពងាយស្រួលដល់អ្នកជម្ងឺចេញចូល
- មានពន្លឺនិងខ្យល់អាកាសចេញចូលគ្រប់គ្រាន់
- នៅឆ្ងាយពីសម្លេង ធូលី ផ្សែង កាកសំណល់ផ្សេង ៗ

កាលណាសហគ្រាស មានសាខា ឬ ការដ្ឋានមួយ ឬច្រើនដែលមានប្រើអ្នកស៊ីឈ្នួលយ៉ាងតិច ៥០ នាក់ ហើយស្ថិតនៅចម្ងាយលើសពី ៥ គីឡូម៉ែត្រ ( ៥ គ.ម ) ពីការដ្ឋានធំនិយោជកត្រូវតែផ្តល់ចំពោះសាខា ឬ ការដ្ឋានទាំងនោះអោយដូច ជាការដ្ឋានធំដែរនូវមធ្យោបាយសង្គ្រោះ និង ព្យាបាលអ្នកស៊ីឈ្នួលខ្លួន អោយបានសព្វគ្រប់ដូចជាបុគ្គលិកពេទ្យ សំលៀង សម្ភារៈវត្ថុរុំរបួស និង ថ្នាំព្យាបាល ។

**ប្រការ ៣ :** គ្រប់រោងចក្រ សហគ្រាសក្រុមហ៊ុនផ្សេង ៗ ដូចបានចែងក្នុងប្រការ ១ ខាងលើត្រូវមានបុគ្គលិកធ្វើការក្នុងគិលានដ្ឋានរបស់ខ្លួន ជាប្រចាំដូចតទៅ ÷

- គ្រូពេទ្យមធ្យម ០១ នាក់ និង គិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកា ០១ នាក់ សំរាប់បុគ្គលិកកម្មករចាប់ពី ៥០ នាក់ ទៅ ២០០ នាក់ ។
- គ្រូពេទ្យមធ្យម ០១ នាក់ និង គិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកា ០២ នាក់ សំរាប់បុគ្គលិកកម្មករ ចាប់ពី ៤០០ នាក់ឡើងទៅ ។
- ក្នុងករណីពិសេស ត្រូវមានវេជ្ជបណ្ឌិត ០១ នាក់ និង គិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកា ០១ នាក់ ឬ ០២ នាក់ ធ្វើការជាប្រចាំផងដែរដោយពុំគិតចំនួនបុគ្គលិក កម្មករឡើយចំពោះរោងចក្រ សហគ្រាស ឬ ក្រុមហ៊ុនណាដែលប្រកបដោយហានិភ័យ ខ្ពស់ ឬ ក្នុងករណី

ដែលក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជនយល់ឃើញថា ចាំបាច់ត្រូវមាន វេជ្ជបណ្ឌិត ធ្វើការជាប្រចាំ ។

- ចំពោះសហគ្រាស ដែលមានវេនម៉ោងធ្វើការទាំងថ្ងៃទាំងយប់ ត្រូវមានគិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកយ៉ាងតិច ០១ នាក់ យាមប្រចាំការជាអចិន្ត្រៃយ៍ ។

**ប្រការ ៤ :** ចំពោះរោងចក្រ សហគ្រាស ឬ ក្រុមហ៊ុនផ្សេង ៗ ណាដែលមានអ្នកស៊ីឈ្នួលតិចជាង ២០ នាក់ ត្រូវមានអ្នកជំនួយសង្គ្រោះ ០១ នាក់ និង ប្រអប់សង្គ្រោះមួយ ។

- ចំពោះរោងចក្រ សហគ្រាស ឬក្រុមហ៊ុនផ្សេង ៗ ណាដែលមានអ្នកស៊ីឈ្នួល ចាប់ពី ២០ នាក់ ទៅ ៥០ នាក់ ត្រូវមានបន្ទប់រុំរបួសមួយ និង គិលានុបដ្ឋាក ឬ គិលានុបដ្ឋាយិកា ០១ នាក់ ។

- ចំពោះសហគ្រាសដែលមានអ្នកស៊ីឈ្នួល មិនគ្រប់ចំនួន និង ត្រូវបង្កើតគិលានដ្ឋាន អចិន្ត្រៃយ៍មួយ សហគ្រាសទាំងនោះអាចរួមសហការ ជាមួយសហគ្រាសផ្សេងដទៃទៀត ដែលស្ថិតនៅជិត ៗ គ្នា ដើម្បីបង្កើតជាគិលានដ្ឋានអចិន្ត្រៃយ៍ មួយហៅថា គិលានដ្ឋានអន្តរ សហគ្រាស ។

**ប្រការ ៥ :** ក- ប្រអប់សង្គ្រោះត្រូវមានជាចាំបាច់ :

- សម្ភារៈរុំរបួស
- សម្ភារៈសម្រាប់សម្លាប់មេរោគ ឱសថផ្សេង ៗ ដូចជាថ្នាំបំបាត់ការឈឺចាប់
- ថ្នាំបញ្ចុះកំដៅ ថ្នាំទប់ទល់នឹងការរាគរូស ក្អួត ថ្នាំប្រឆាំងនឹងការរលាកភ្លើង
- ប្រេងខ្យល់ ប្រេងកូឡា ជាដើម ។

ខ- បន្ទប់រុំរបួស ត្រូវមានជាចាំបាច់នូវ :

- ប្រអប់សង្គ្រោះមួយ
- គ្រែរបួសមួយ
- តុ កៅអី
- ភ្លើងបំភ្លឺ

គ- គិលានដ្ឋាន :

ក្នុងគិលានដ្ឋាននិមួយ ៗ ត្រូវមានគ្រែ ០២ យ៉ាងតិច " គ្រែមួយសំរាប់ព្យាបាលជំងឺ គ្រែមួយទៀតសំរាប់សង្គ្រោះបន្ទាន់ " ។

កាលណាចំនួនអ្នកស៊ីឈ្នួលមានច្រើនជាង ៤០០ នាក់ ក្រៅពីគ្រឿងរុំរបួស និង ថ្នាំ

ព្យាបាល តិលានដ្ឋានត្រូវមាន កន្លែងសំរាប់អោយអ្នករបួស និង អ្នកជំងឺសំរាក មុននឹងបញ្ជូនទៅមន្ទីរពេទ្យធំ ឬសំរាប់ដាក់អ្នកជំងឺអោយសំរាកនៅឆ្ងាយពីគេ កាលណាត្រូវការ ។ ទីកន្លែងទាំងនោះត្រូវមានលទ្ធភាពដាក់អ្នកជំងឺសំរាកអោយបាន ០២ ភាគរយ នៃអ្នកស៊ីឈ្នួលដែលប្រើក្នុងការដ្ឋាន ។

ក្រៅពីវិធានការដែលចែងខាងលើ និយោជកត្រូវតែចាត់ចែង ដោយចេញសោហ៊ុយខ្លួនឯងនូវ :

១- ក្រុម គីមីញ៉ូ ពង្គាររោគនៅក្នុងការដ្ឋានខ្លួន

២- ការចាក់ថ្នាំការពារជំងឺឆ្លងទាំងឡាយដោយប្រើស៊ីរាំង និង ម្ជុលចាក់ម្តងចោល ។

**ប្រការ ៦ :** សោហ៊ុយចំណាយក្នុងការរៀបចំតិលានដ្ឋាន និង ការប្រព្រឹត្តទៅ នៃក្រុមពេទ្យការងារព្រមទាំងការព្យាបាល ថែទាំ និង អាហារ នៃអ្នករបួស និង អ្នកជំងឺសំរាកក្នុង តិលានដ្ឋានសហគ្រាស ត្រូវនៅក្នុងបន្ទុកនិយោជក ។

**ប្រការ ៧ :** ការប្រព្រឹត្តល្មើស ឬ មិនអនុវត្តតាមបទបញ្ញត្តិទាំងឡាយ នៃប្រកាសនេះ ត្រូវពិន័យជាប្រាក់ ឬទទួលទោសដូចមានចែងក្នុងមាត្រា ២៨៦ - ២៨៧- ២៨៨ នៃច្បាប់ការងារ ។

**ប្រការ ៨ :** ប្រកាសនេះ មានប្រសិទ្ធភាព អនុវត្តចាប់ពីពេលចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

វេជ្ជ. ឈា ថាំង

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច
ការងារ នឹង អតីតយុទ្ធជន

ស៊ុយ សែម

******